ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី អន្តរាគមជួយពលការិនីខ្មែរ៣នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**៣នាក់** ដូចខាងក្រោម៖

(១) ពលការិនី **ជ.គ** អាយុ៤៣ឆ្នាំ មកពីស្រុកស្ទឹងសែន ខេត្តកំពង់ធំ បានទៅម៉ាឡេស៊ី ធ្វើការតាមផ្ទះ កាលពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ តាមរយៈមេខ្យល់។ ដោយសារការងារលំបាកពេក និងនិយោជកមិនបើកប្រាក់ខែឲ្យ ពលការិនីបានទៅស្ថានទូត នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៧ ដើម្បីស្នើស្ថានទូតជួយទាមទារប្រាក់ខែដែលនៅសល់ពីនិយោជក និងជួយនាងឲ្យបានវិលត្រឡប់មកកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនី បានយល់ព្រមប្រគល់ប្រាក់ខែដែលនៅសល់ ជូននាងវិញ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧។

(២) ពលការិនី **ព.ទ** អាយុ ៣៧ឆ្នាំ មកពីស្រុកបាធាយ ខេត្តកំពង់ចាម បានធ្វើដំណើរតាមរថយន្តឆ្លងកាត់ប្រទេសថៃ ចូលទៅប្រទេសម៉ាឡេស៊ីដោយខុសច្បាប់ និងធ្វើការតាមផ្ទះ កាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៦ តាមរយៈមេខ្យល់។ ដោយពុំចង់ធ្វើការបន្តទៀត នាងបានទៅស្ថានទូត នៅថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៧ ស្នើជួយឲ្យបានវិលត្រឡប់មកកម្ពុជាវិញ។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយពលការិនីទាំងពីរបានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី **២៩** ខែ **ឧសភា** ឆ្នាំ **២០១៧** វេលាម៉ោង**១៧:៣៥**នាទី តាមជើងយន្តហោះ MH762 ។

(៣) ពលការិនី **ឈ.ចដ** អាយុ២០ឆ្នាំ មកពីសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ បានធ្វើដំណើរតាមរថយន្តឆ្លងកាត់ប្រទេសថៃ ចូលទៅប្រទេសម៉ាឡេស៊ីដោយខុសច្បាប់ និងធ្វើការតាមផ្ទះ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ តាមរយៈក្រុមហ៊ុនមួយ (មិនចាំឈ្មោះ) នៅកម្ពុជា។ ដោយការងារលំបាកពេក ពលការិនីបានទៅស្ថានទូត នៅថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៧ ដើម្បីស្នើសុំជួយទាមទារប្រាក់ខែដែលនៅសល់ពីនិយោជក និងជួយនាងឲ្យបានវិលត្រឡប់មកកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនី បានទៅស្ថានទូតនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១៧ ហើយបានប្រគល់ប្រាក់ខែដែលនៅសល់ និងទិញសំបុត្រយន្តហោះជូននាង។ ពល-ការិនីខាងលើ នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី **០២** ខែ **មិថុនា** ឆ្នាំ **២០១៧** វេលាម៉ោង**១៥:៥៥**នាទី តាមជើងយន្តហោះ AK534 ។

ភ្នំពេញ, ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ